Fujifilm Group

# កតិកាសញ្ញាស្ដីពីឥរិយាបថសាជីវកម្ម និងក្រមនៃការប្រព្រឹត្តរបស់

FUJIFILM

Value from Innovation



# ការប្តេជ្ញាចិត្តរបស់ Fujifilm Group

យើងដាក់គោលដៅសម្រេចឲ្យបាននូវគោលបំណងរបស់សម្ព័ន្ធក្រុមហ៊ុន ដោយប្រកាន់ខ្ជាប់នូវបំណងប្រាថ្នាដ៏ពិតប្រាកដ។

គោលបំណងរបស់Fujifilm Group

## ផ្តល់ឲ្យពិភពលោកនូវស្នាមញញឹមកាន់តែច្រើន

យើងនាំមកនូវគំនិតបែបចម្រុះ សមត្ថភាពពិសេស
និងប្រមូលធនធានមនុស្សឆ្នើម ដើម្បីផ្លាស់ប្តូរពិភពលោក។

ពាក្យស្លោកសាជីវកម្ម

## តម្លៃកើតចេញពីការច្នៃប្រឌិត (Value from Innovation)

ច្បាប់របស់Fujifilm Group សម្រាប់តរិយាបថសាជីវកម្ម និងក្រមសីលធម៌

យើងអនុវត្តសកម្មភាពទាំងអស់របស់យើង ដោយឈរលើស្មារតី “បើកចំហ យុត្តិធម៌ និងច្បាស់លាស់“។

### កតិកាសញ្ញាស្តីពីតរិយាបថសាជីវកម្ម

១. ក្រុមហ៊ុនដែលទទួលបាននូវទំនុកចិត្ត
២. ទំនួលខុសត្រូវសង្គម
៣. ការគោរពសិទ្ធិមនុស្ស
៤. ការអភិរក្សបរិស្ថានជាសកល
៥. កន្លែងការងារមានភាពរីករាយ
៦. ការគ្រប់គ្រងវិបត្តិផ្សេងៗ

### ក្រមនៃការប្រព្រឹត្ត

គ្រប់ផ្នែកទាំងអស់នៃសកម្មភាពសាជីវកម្មរបស់យើង យើងផ្តោតសំខាន់លើអនុសញ្ញា និងខិតខំប្រឹងប្រែងបង្កើតនូវគុណតម្លៃថ្មីៗ។ ករណីដែលលក្ខខណ្ឌតម្រូវនៃ អនុសញ្ញាភាពប្រឆាំងទៅនឹងផលប្រយោជន៍អាជីវកម្ម ឬ តំរូវការរបស់ភាគីទីបី យើងនឹងផ្តល់អាទិភាពទៅលើ អនុសញ្ញា។

១. ការគោរពចំពោះសិទ្ធិមនុស្ស
២. សកម្មភាពសាជីវកម្មប្រកបដោយយុត្តិធម៌
៣. ការការពារ/អភិរក្សទ្រព្យសម្បត្តិ និងព័ត៌មានសាជីវកម្ម
៤. វិធានការពាក់ព័ន្ធនឹងបញ្ហាបរិស្ថាន

# ការប្តេជ្ញាចិត្តចំពោះច្បាប់របស់Fujifilm Group សម្រាប់ឥរិយាបថសាជីវកម្ម និងក្រមសីលធម៌

Fujifilm Group តែងតែបានជំរុញនូវការច្នៃប្រឌិត ក្នុងពេលដំណាលគ្នានឹងការបំប្លែងអាជីវកម្មរបស់ខ្លួន ដើម្បីឲ្យសមស្របទៅនឹងពេលវេលានៃការផ្លាស់ប្តូរ។ ការផ្លាស់ប្តូរដ៏ឆាប់រហ័សក្នុងសង្គម ដែលបាន និងកំពុងតែកើតឡើងក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ តម្រូវឱ្យយើងដោះស្រាយបញ្ហាមួយចំនួនដែលកាន់តែស្មុគស្មាញ និងស្មុគស្មាញ កើនឡើងជាលំដាប់ដូចជា ហានិភ័យភូមិសាស្ត្រនយោបាយ បម្រែបម្រួលអាកាសធាតុនិងគ្រោះធម្មជាតិ បញ្ហាបរិស្ថាន សិទ្ធិមនុស្ស សុខភាព ពលកម្ម និងការគ្រប់គ្រងព័ត៌មាន ជាដើម។ តម្រូវការ និងច្បាប់របស់សង្គមតែងតែមានការផ្លាស់ប្តូរ ដូច្នេះវាមានសារៈសំខាន់ក្នុងការធានាថា យើងអាចបន្តការរីកលូតលាស់ប្រកបដោយភាពសុខដុមរមនា រួមជាមួយនឹងភាគីពាក់ព័ន្ធរបស់យើង ដែលខិតខំធ្វើឲ្យមានតុល្យភាពរវាងអាជីវកម្ម និងបានគិតគួរដល់សង្គមយ៉ាងឆាប់រហ័ស និងមិនជាប់គាំងដោយសារកិច្ចព្រមព្រៀង ឬ ការកំណត់ទុក។

ជាការពិត Fujifilm Groupនឹងជួបប្រទះបញ្ហាលំបាកជាច្រើនទៀត ក្នុងពេលខាងមុខហើយនៅពេលដែលយើងជួបប្រទះនូវរឿងរ៉ាវទាំងនោះ ឥរិយាបថសាជីវកម្ម និងក្រមសីលធម៌ នឹងដើរតួជាអ្នកនាំផ្លូវដ៏សំខាន់។ ច្បាប់នៃឥរិយាបថសាជីវកម្មបានធ្វើការសង្ខេបពីគោលការណ៍មូលដ្ឋានរបស់Fujifilm Group  សម្រាប់ការធ្វើសកម្មភាពសាជីវកម្ម ខណៈដែលក្រមសីលធម៌នឹងបញ្ជាក់ពីរបៀបដែលយើងគួរអនុវត្តក្នុងស្ថានភាពផ្សេងៗ។ រៀងរាល់ឆ្នាំ ក្នុងខែមេសា បុគ្គលិកទាំងអស់របស់Fujifilm Group នៅជុំវិញពិភពលោក តែងតែប្រកាសអំពីចេតនារបស់ពួកគេ ក្នុងការអាន ស្វែងយល់ អនុវត្តតាម និងប្រព្រឹត្តដោយយោងតាមឯកសារទាំងអស់នេះ ហើយចាប់ផ្តើមក្នុងឆ្នាំថ្មីជាមួយនឹងការធ្វើការងារ ដោយភាពស្វាហាប់សាជាថ្មី។ ដោយសារអ្វីគ្រប់យ៉ាងដែលយើងធ្វើ គឺ ផ្អែកលើវប្បធម៌សាជីវកម្ម “បើកចំហ យុត្តិធម៌ និងច្បាស់លាស់” ខ្ញុំសុំស្នើឲ្យអ្នកយោងទៅតាមច្បាប់សម្រាប់ឥរិយាបថសាជីវកម្ម និងក្រមសីលធម៌ ដើម្បីឲ្យប្រាកដថាអ្នកអាចមានមោទនភាពចំពោះសកម្មភាពណាមួយដែលអ្នកធ្វើ ដែលជាផ្នែកនៃសកម្មភាពអាជីវកម្មប្រចាំថ្ងៃរបស់អ្នក ក្នុងនាមជាសមាជិកមួយរូបរបស់ Fujifilm Group។

ខ្ញុំសុំប្រកាសថា ខ្ញុំនឹងអនុវត្តតាមច្បាប់របស់Fujifilm Group សម្រាប់ឥរិយាបថសាជីវកម្ម និងក្រមសីលធម៌។ ខ្ញុំសុំឲ្យអ្នកទាំងអស់គ្នាយល់ឲ្យបានពេញលេញ និងអនុវត្តតាមគោលការណ៍ទាំងនេះ ចំពោះអ្វីគ្រប់យ៉ាងដែលអ្នកធ្វើ។ ចូរយើងធ្វើការជាមួយគ្នា ដើម្បីជម្នះបញ្ហាប្រឈម និងរាល់ការលំបាក ដែលយើងប្រាកដជាប្រឈមនៅពេលយើងធ្វើដំណើរឆ្ពោះទៅមុខ ហើយបង្កើតលទ្ធផលវិជ្ជមាន ដែលនឹងផ្តល់ឲ្យពិភពលោកនូវស្នាមញញឹមកាន់តែច្រើន។

ខែមករា ឆ្នាំ២០២៤



តេអ៊ិឈិ ហ្គូតូ
ប្រធាន នាយកតំណាង និងនាយកប្រតិបត្តិ
ប្រធាននៃគណៈកម្មការសង្គមបរិស្ថាន និងអភិបាលកិច្ច
FUJIFILM Holdings Corporation

# បញ្ញត្តិទូទៅ៖

## 1. វិសាលភាពនៃការអនុវត្ត

កតិកាសញ្ញាស្តីពីឥរិយាបថសាជីវកម្ម និង ក្រមនៃការប្រព្រឹត្តនេះ ត្រូវអនុវត្តចំពោះបុគ្គលិកប្រតិបត្តិ និងនិយោជិតគ្រប់រូបរបស់Fujifilm Holdings Corporation និងសម្ព័ន្ធក្រុមហ៊ុនរបស់ខ្លួនទាំងអស់។ ម្យ៉ាងទៀត ភាគីពាក់ព័ន្ធនានារួមទាំងអ្នកម៉ៅការ បុគ្គលិកដែលបានបញ្ជូនឲ្យទៅធ្វើការ អ្នកតំណាងផ្នែកលក់ ដៃគូអាជីវកម្មពាក់ព័ន្ធនឹងការផ្តល់ជូនផលិតផល និងសេវាកម្មរបស់ក្រុមហ៊ុន Fujifilm Group ត្រូវបានស្នើសុំឲ្យគោរពតាម កតិកាសញ្ញាស្តីពីឥរិយាបថសាជីវកម្ម និង ក្រមនៃការប្រព្រឹត្តនៅក្នុងការអនុវត្តការងារនោះ។

## 2. នីតិវិធីសម្រាប់ការបង្កើត និងការកែសម្រួល

ការបង្កើត និងការកែសម្រួល កតិកាសញ្ញាស្តីពីឥរិយាបថសាជីវកម្ម និង ក្រមនៃការប្រព្រឹត្តនេះ ត្រូវបានសម្រេចដោយគណៈកម្មការ ESG នៃ FUJIFILM Holdings Corporation។ កតិកាសញ្ញាស្តីពីឥរិយាបថសាជីវកម្មនិង ក្រមនៃការប្រព្រឹត្ត និងបទប្បញ្ញត្តិនានា ត្រូវអនុវត្តចំពោះសម្ព័ន្ធក្រុមហ៊ុននីមួយៗ នៅពេលមានការជូនដំណឹងពីFUJIFILM Holdings Corporation។

## 3. ស្តង់ដារនៃច្បាប់

កតិកាសញ្ញាស្តីពីឥរិយាបថសាជីវកម្ម និង ក្រមនៃការប្រព្រឹត្តនេះ ត្រូវចែងអំពីវិធានរួមដែលត្រូវអនុវត្តដោយបុគ្គលិកប្រតិបត្តិ និងនិយោជិតទាំងអស់ របស់FUJIFILM Holdings Corporation និងសម្ព័ន្ធក្រុមហ៊ុនរបស់ខ្លួន។ រាល់បុគ្គលិកប្រតិបត្តិ និងនិយោជិតទាំងអស់ រំពឹងថាមិនត្រឹមតែអនុវត្តតាមវិធានទាំងនេះប៉ុណ្ណោះទេ តែថែមទាំងបង្ហាញនូវការវិនិច្ឆ័យ និងឥរិយាបថប្រកបដោយក្រមសីលធម៌ខ្ពស់ ឆ្លើយតបទៅនឹងការរំពឹងទុករបស់សង្គម និងមូលដ្ឋានរបស់ពួកគេ។

## 4. ការធានាលើការប្រតិបត្តិតាមច្បាប់

ក្រុមហ៊ុន និងនិយោជិត រំពឹងថាត្រូវ ធ្វើការងារស្របតាម កតិកាសញ្ញាសម្រាប់ឥរិយាបថអាជីវកម្ម និង ក្រមនៃការប្រព្រឹត្តនេះ។ បុគ្គលិកប្រតិបត្តិ និងបុគ្គលិកគ្រប់គ្រង រួមទាំងមន្ត្រីប្រតិបត្តិដែលទទួលបន្ទុកតាមផ្នែក អ្នកគ្រប់គ្រងទូទៅ និងអ្នកគ្រប់គ្រង FUJIFILM Holdings Corporation និងសម្ព័ន្ធក្រុមហ៊ុននីមួយៗ ត្រូវទទួលខុសត្រូវលើការគ្រប់គ្រងលើការអនុវត្ត កតិកាសញ្ញាស្តីពីឥរិយាបថសាជីវកម្ម និង ក្រមនៃការប្រព្រឹត្តនេះក្នុងក្របខណ្ឌស្ថាប័នរចនាសម្ព័ន្ធដែលពួកគេគ្រប់គ្រង។

## 5. ទណ្ឌកម្ម និងការពិន័យប្រឆាំងនឹងការរំលោភច្បាប់

ក្នុងករណីដែលបុគ្គលិកគ្រប់គ្រង ឬនិយោជិតណាម្នាក់បំពានលើ ក្រមនៃការប្រព្រឹត្តនេះ បុគ្គលិកនោះត្រូវគោរពតាមវិធានការវិន័យ ឬ ផលវិបាកផ្សេងទៀតស្របទៅតាមបទប្បញ្ញត្តិជាធរមាននៃក្រុមហ៊ុន the Fujifilm Group។ ក្នុងករណីការបំពានច្បាប់នេះបង្កការខូចខាតដល់ក្រុមហ៊ុន នោះក្រុមហ៊ុនអាចចាត់វិធានការផ្លូវច្បាប់នានា ដោយរាប់បញ្ចូលការស្វែងរកសំណងចំពោះការខូចខាតទាំងនោះ។




# ក្រុមហ៊ុន Fujifilm Group៖ កតិកាសញ្ញាស្តីពីឥរិយាបថសាជីវកម្ម

ក្រៅពីការស្វែងរកផលចំណេញតាមរយៈការប្រកួតប្រជែងដោយយុត្តិធម៌ ក្រុមហ៊ុនសាជីវកម្មត្រូវតែផ្តល់វិភាគទានចូលរួមនៅក្នុងសង្គម ឲ្យបានច្រើន។ ដើម្បីសម្រេចគោលដៅនេះ អនុលោមតាមគោលទាំងប្រាំមួយខាងក្រោមនេះ នៅក្នុងសកម្មភាពសាជីវកម្មរបស់ខ្លួននៅប្រទេសជប៉ុន និងនៅក្រៅប្រទេស ក្រុមហ៊ុន Fujifilm Group ត្រូវគោរពសិទ្ធិមនុស្សក៏ដូចជាគោរពចំពោះស្មារតី និងលិខិតបទដ្ឋានច្បាប់ បទប្បញ្ញត្តិ និងវិធានអន្តរជាតិទាំងអស់ផងដែរ។ លើសពីនេះ ក្រុមហ៊ុនធ្វើការពិចារណាអំពីផលប៉ះពាល់នៃសកម្មភាពរបស់ខ្លួន ហើយតាមរយៈភាពច្នៃប្រឌិត ក្រុមហ៊ុនបានធ្វើការងារយ៉ាងសកម្មឆ្ពោះទៅរកការបង្កើតនូវសង្គមប្រកបដោយចេរភាពមួយ។

## 1. ក្រុមហ៊ុនដែលទទួលបាននូវទំនុកចិត្ត

យើងបានអភិវឌ្ឍ និងផ្តល់ផលិតផល និងសេវាកម្មមានគុណភាពខ្ពស់បំផុត ប្រកបដោយអត្ថប្រយោជន៍ដល់សង្គម ដោយប្រើប្រាស់នូវបច្ចេកវិទ្យាដើមដំបូង និងទំនើបបំផុតប្រកបដោយសុវត្ថិភាព និងមានទំនួលខុសត្រូវ។ ផ្អែកលើវប្បធម៌សាជីវកម្មបើកទូលាយ យុត្តិធម៌ និងច្បាស់លាស់ យើងបង្កើតនូវគុណតម្លៃថ្មីៗនៅក្នុងស្មារតីប្រកួតប្រជែងសមស្រប និងធ្វើអាជីវកម្មយ៉ាងយុត្តិធម៌។ យើងខិតខំប្រឹងប្រែងជាបន្តដើម្បីបំពេញតម្រូវការអតិថិជន និងភាគីពាក់ព័ន្ធផ្សេងទៀត ដើម្បីទទួលបាននូវទំនុកចិត្តពីពួកគេ ឆ្ពោះទៅរកការរីកចម្រើន ទាំងអស់គ្នា។

## 2. ទំនួលខុសត្រូវសង្គម

យើងប្រាស្រ័យទាក់ទងជាមួយភាគីពាក់ព័ន្ធនានាជាច្រើនដូចជាអតិថិជន ដៃគូអាជីវកម្ម និយោជិត សហគមន៍ក្នុងមូលដ្ឋាន ទីភ្នាក់ងាររដ្ឋាភិបាល ម្ចាស់ភាគហ៊ុន និងអ្នកវិនិយោគទុន អង្គការក្រៅរដ្ឋាភិបាល (NGO) និងអង្គការមិនស្វែងរកប្រាក់ចំណេញ (NPO) ហើយធ្វើការផ្សព្វផ្សាយយ៉ាងសមស្របនិងត្រឹមត្រូវនូវព័ត៌មានសាជីវកម្ម។ ម្យ៉ាងទៀត យើងគោរពតាមច្បាប់ បទប្បញ្ញត្តិ និងវិធានផ្សេងទៀត ហើយលើកកំពស់សណ្តាប់សាធារណៈ និងក្រមសីលធម៌។ ក្នុងនាមជាពលរដ្ឋល្អ សាជីវកម្មល្អយើងខិតខំស្វែងយល់ និងគោរពយ៉ាងត្រឹមត្រូវតាមវប្បធម៌និងប្រពៃណីក្នុងស្រុក និងមានបំណងអនុវត្តសកម្មភាពនានាដែលមានការចូលរួមពីសហគមន៍។ លើសពីនេះទៀត យើងមានគោលដៅលើកស្ទួយសហគមន៍មូលដ្ឋានតាមរយៈការបង្កើតការងារ និងលើកម្ពស់សង្គមប្រកបដោយចេរភាពមួយ។

## 3. ការគោរពសិទ្ធិមនុស្ស

យើងគោរពសិទ្ធិមនុស្សដែលមានចែងនៅក្នុងសេចក្តីប្រកាសអន្តរជាតិ។ យើងគិតគូរដល់អ្នកដែលងាយរងគ្រោះ និងជំទាស់ទៅនឹងការប្រើប្រាស់កម្លាំងពលកម្មដោយបង្ខំ ឬពលកម្មកុមារគ្រប់រូបភាពទាំងអស់ ហើយក្រៅពីការគោរពតាមច្បាប់ស្តីពីប្រាក់កម្រៃអប្បបរមាក្នុងស្រុកនៃប្រទេសនីមួយៗ និងនៅក្នុងតំបន់ យើងមានការយល់ដឹងអំពីសារៈ សំខាន់នៃប្រាក់កម្រៃសមស្របដែលជំរុញឲ្យបុគ្គលិកមានលទ្ធភាពរ៉ាប់រងលើថ្លៃចំណាយនៅក្នុងជីវភាពរស់នៅប្រកបដោយសុខភាពល្អ និងសមស្របតាមវប្បធម៌។

## 4. ការអភិរក្សបរិស្ថានជាសកល

ដោយមានការទទួលស្គាល់ថាការចូលរួមជាវិជ្ជមាននៅក្នុងការ ទទួលខុសត្រូវលើបរិស្ថាន គឺជាផ្នែកមួយដ៏សំខាន់ នៃសកម្មភាព និងតួនាទីសង្គមរបស់ក្រុមហ៊ុនសាជីវកម្ម ដូច្នេះយើងនឹងធ្វើសកម្មភាពដោយស្ម័គ្រចិត្ត និងយ៉ាងសកម្មដើម្បីជួយដោះស្រាយរាល់បញ្ហាប្រឈមផ្នែកបរិស្ថានផ្សេងៗជាច្រើន មានជាអាទិ៍តាមរយៈការដោះស្រាយការប្រែប្រួលអាកាសធាតុ ការអភិរក្សជីវចម្រុះ ការបង្កើតប្រព័ន្ធសេដ្ឋកិច្ចវិលជុំ និងធានានូវសុវត្ថិភាពសារធាតុគីមី។

## 5. កន្លែងការងារមានភាពរីករាយ

យើងព្យាយាមអភិវឌ្ឍជំនាញ របស់និយោជិតគ្រប់រូប ផ្តល់នូវកន្លែងការងារដែលមានសុវត្ថិភាព និងមានភាពងាយស្រួល និងគោរពនូវភាពចម្រុះបុគ្គលិកលក្ខណៈ និងបុគ្គលភាពរបស់និយោជិតទាំងអស់។

## 6. ការគ្រប់គ្រងវិបត្តិផ្សេងៗ

យើងនឹងធានានូវការគ្រប់គ្រងវិបត្តិជាប្រព័ន្ធ ក្នុងការឆ្លើយតបទៅនឹងហានិភ័យដែលអាចគំរាមកំហែងដល់ជីវិតពលរដ្ឋ និងសកម្មភាពសាជីវកម្មនានា ដូចជាគ្រោះមហន្តរាយធម្មជាតិ ភេរវកម្ម ការវាយប្រហារតាមប្រព័ន្ធអ៊ីនធឺណិត និងបទល្មើសគ្រោងទុកជាមុន។

ដោយមានការទទួលស្គាល់ទំនួលខុសត្រូវរបស់ថ្នាក់គ្រប់គ្រងជាន់ខ្ពស់ចំពោះការដាក់បញ្ចូលនូវគោលការណ៍នៃ កតិកាសញ្ញានេះ ដូច្នេះបុគ្គលិកប្រតិបត្តិរបស់ Fujifilm Group ត្រូវដឹកនាំធ្វើជាគំរូ និងលើកកម្ពស់ការយល់ដឹងត្រឹមត្រូវអំពី កតិកាសញ្ញានេះ ទាំងនៅក្នុងសម្ព័ន្ធក្រុមហ៊ុន និងក្នុងចំណោមដៃគូអាជីវកម្ម។ ពួកគេត្រូវបន្តខិតខំប្រឹងប្រែងពិចារណាលើទស្សនៈនានាទាំងក្នុង និងក្រៅសម្ព័ន្ធ ក្រុមហ៊ុន បង្កើតនូវប្រព័ន្ធសាជីវកម្មដ៏មានប្រសិទ្ធភាព និងជំរុញនូវស្តង់ដារសីលធម៌ខ្ពស់។

ករណីមានស្ថានការណ៍នានាដែលប្រឆាំងនឹង កតិកាសញ្ញានេះ ថ្នាក់គ្រប់គ្រងជាន់ខ្ពស់ ត្រូវបញ្ជាក់ឲ្យបានច្បាស់ទាំងក្នុង និងក្រៅក្រុមហ៊ុន អំពីអភិក្រមរបស់ខ្លួននៅក្នុងការដោះស្រាយស្ថានការណ៍ទាំងនោះ ហើយប្រឹងប្រែងកំណត់ពីបុព្វហេតុ និងការពារមិនឲ្យស្ថានការណ៍នោះកើតឡើងសាជាថ្មី។ ថ្នាក់គ្រប់គ្រងជាន់ខ្ពស់របស់ក្រុមហ៊ុន ត្រូវមានទំនួលខុសត្រូវ ផ្សព្វផ្សាយព័ត៌មានឲ្យបានទាន់ពេលវេលានិងសមស្រប ហើយត្រូវចាត់វិធានការវិន័យយ៉ាងតឹងរឹងតាមពេលវេលាសមស្រប រួមទាំងចាត់វិធានការវិន័យពាក់ព័ន្ធនឹងខ្លួនឯងផង ដែរ។

# ក្រុមហ៊ុន Fujifilm Group៖ ក្រមនៃការប្រព្រឹត្ត៖

## សេចក្តីផ្តើម

បច្ចុប្បន្ននេះ ពិភពលោកកំពុងជួបប្រទះឧបសគ្គច្រើនរាប់មិនអស់។ ដើម្បីផ្តល់ជូននូវសង្គមដ៏សម្បូរបែបនិងមានភាពរីករាយមួយ ទៅដល់មនុស្សជំនាន់ក្រោយ យើងចាំបាច់ត្រូវដោះស្រាយឧបសគ្គសង្គមជាច្រើនដែលពាក់ព័ន្ធនឹងបរិស្ថាន ថាមពល ស្បៀងអាហារ សុខភាពនិងវេជ្ជសាស្ត្រ សុវត្ថិភាព និងការបង្ការគ្រោះធម្មជាតិ និងការគោរពសិទ្ធិមនុស្ស ដោយធានាបាននូវកំណើនសេដ្ឋកិច្ចក្នុងពេលដំណាលគ្នានេះផងដែរ។ ក្រុមហ៊ុន រំពឹងថានឹងរួមចំណែកទៅក្នុងការដោះស្រាយឧបសគ្គទាំងនេះ និងទៅក្នុងការបង្កើតនូវសង្គមប្រកបដោយនិរន្តរភាព តាមរយៈការបង្កើតឡើងនៅក្នុងកិច្ចសហការជាមួយភាគីពាក់ព័ន្ធផ្សេងៗ។

ដើម្បីសម្រេចគោលដៅនេះ របៀបរបបដែល យើងអនុវត្តសកម្មភាពអាជីវកម្មរបស់យើង គឺមានសារៈសំខាន់បំផុត។ យើងត្រូវតែធានាថា យើងចូលរួមជាមួយភាគីពាក់ព័ន្ធ និងជំរុញឲ្យមាននូវកិច្ចសន្ទនាផ្លោះប្តូរយោបល់គ្នាទៅវិញទៅមក (ភាពបើកចំហ) គោរពវិន័យដោយស្មើភាពគ្នា និងឥតលម្អៀង (យុត្តិធម៌) មានទំនួលខុសត្រូវចំពោះការធ្វើសេចក្តីសម្រេចចិត្ត និងសកម្មភាពផ្ទាល់ខ្លួន និងធានានូវតម្លាភាពដោយភាពស្មោះត្រង់ និង សុចរិតភាព (ភាពច្បាស់លាស់)។ ច្បាប់ និងវិធានផ្សេងៗជាច្រើនកើតមាននៅក្នុងសង្គម។ ក្នុងពិភពអាជីវកម្ម ដូចជានៅក្នុងជីវិតរស់នៅប្រចាំថ្ងៃរបស់យើងក្នុងនាមជាសមាជិកសង្គម គុណតម្លៃសង្គមរបស់យើង ត្រូវបានកំណត់ដោយការអនុលោមតាមច្បាប់ និងវិធានទាំងនោះ។

ដើម្បីធានាថាយើងបន្តស្ថិតនៅជាក្រុមហ៊ុនដែលសង្គមត្រូវការ និងមានទំនុកចិត្តនោះ យើងនឹងបង្កើតនូវគុណតម្លៃសម្រាប់ ការស្ថាបនាសង្គមប្រកបដោយនិរន្តរភាពមួយ ដោយកំណត់យកអនុលោមភាពធ្វើជាមូលដ្ឋាននៃរាល់កិច្ចខិតខំប្រឹងប្រែង ទាំងអស់របស់យើង។

## សេចក្តីថ្លែងការស្តីពីអនុលោមភាពនៃFujifilm Group

Fujifilm Group កំណត់និយមន័យនៃពាក្យ "អនុសញ្ញា" មានន័យលើសពីការមិនបំពានច្បាប់។ យើងជឿជាក់ថា អនុសញ្ញារួមបញ្ចូលនូវការប្រព្រឹត្តខ្លួនត្រឹមត្រូវ ផ្អែកលើសុភវិនិច្ឆ័យ និងក្រមសីលធម៌។ គ្រប់ផ្នែកទាំងអស់នៃសកម្មភាពសាជីវកម្មរបស់យើង យើងផ្តោតសំខាន់លើអនុសញ្ញា និងខិតខំប្រឹងប្រែងបង្កើតនូវគុណតម្លៃថ្មីៗ។ ករណីដែលលក្ខខណ្ឌតម្រូវនៃ អនុសញ្ញាភាពប្រឆាំងទៅនឹងផលប្រយោជន៍អាជីវកម្ម ឬ តំរូវការរបស់ភាគីទីបី យើងនឹងផ្តល់អាទិភាពទៅលើ អនុសញ្ញា។ វប្បធម៌សាជីវកម្មបើកទូលាយ យុត្តិធម៌ និងច្បាស់លាស់មួយ គឺជាមូលដ្ឋានសម្រាប់សកម្មភាពទាំងអស់របស់យើង។



# 1. ការគោរពចំពោះសិទ្ធិមនុស្ស

ទិដ្ឋភាពជាមូលដ្ឋាន និងមានសារៈសំខាន់បំផុតសម្រាប់ពួកយើងម្នាក់ៗ គឺសិទ្ធិមនុស្ស។ សេចក្តីថ្លៃថ្នូររបស់បុគ្គល គឺជាស្នូលនៃសិទ្ធមនុស្សតាមធម្មជាតិរបស់យើង ហើយប្រសិនបើសិទ្ធិនេះមិនត្រូវបានគោរពនោះទេ និយោជិតទាំងឡាយដែលមានសារៈសំខាន់បំផុតសម្រាប់ការលូតលាស់របស់ក្រុមហ៊ុន មិនអាចបំពេញនូវសក្តានុពលរបស់ខ្លួនបានពេញលេញឡើយ ហើយយើងមិនអាចបន្តធ្វើជាក្រុមហ៊ុនមួយដែលសង្គមត្រូវការ និងផ្តល់តម្លៃទៀតនោះទេ។
ការអង្កេតមើលចំណុចដូចខាងក្រោមនឹងបង្កើតបាននូវមូលដ្ឋានសម្រាប់ពួកយើងនៅក្នុងការបង្កើនជាអតិបរមានូវសក្តានុពលរបស់បុគ្គលិកគ្រប់រូបដែលទទួលឥទ្ធិពលដោយផ្ទាល់ ឬដោយប្រយោលពីសកម្មភាពអាជីវកម្មរបស់យើង ក៏ដូចជានៅក្នុងការបង្កើតគុណតម្លៃសង្គមផងដែរ។

## (1) ការគោរពសិទ្ធិមនុស្ស

យើងគោរព និងមិនបំពារបំពានលើសិទ្ធិមនុស្ស ដែលបានធានាដោយសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងសេចក្តីប្រកាសជាអន្តរជាតិ អនុសញ្ញា សេចក្តីណែនាំ និងច្បាប់និងបទប្បញ្ញត្តិជាធរមានផ្សេងទៀត ព្រមទាំងករណីយុត្តិសាស្ត្ររបស់ តុលាការផងដែរ។

## (2) ការគោរព និងការលើកម្ពស់ភាពចម្រុះគ្នា

យើងនឹងប្រកាន់យកនូវភាពចម្រុះ ដើម្បីបង្កើតនូវគុណតម្លៃថ្មីៗ និងរួមចំណែកទៅក្នុងសង្គមមួយដែលសម្បូរបែប តាមរយៈការគោរព ការទទួលយក និងការបណ្តុះនូវបុគ្គលិកលក្ខណៈ និងបុគ្គលភាពរបស់និយោជិត ម្នាក់ៗ ដោយគ្មានការរើសបន្លឺងលើភាពខុសគ្នានៃសាវតា និងជំនឿអ្វីឡើយ។

## (3) ការហាមឃាត់ និងការរើសអើង

យើងគោរពគ្នាទៅវិញទៅមកក្នុងនាមជាបុគ្គលម្នាក់ៗ និងមិនមានការរើសអើងដោយផ្អែកលើមូលដ្ឋានសញ្ជាតិ អាយុ យែនឌ័រ ទំនោរផ្លូវភេទ ឬ អត្តសញ្ញាណភេទ ជាតិសាសន៍ សាសនា គំនិតនយោបាយ មនោគមវិជ្ជា ដើមកំណើតជាតិសាសន៍ឬសង្គម ឬពិការភាពជាដើម ហើយយើងក៏មិន ពឹងផ្អែកលើការសម្រេចចិត្តពាក់ព័ន្ធនឹងការជួលបុគ្គលិកបម្រើការងារ ការដំឡើងឋានៈឬតួនាទីការងារ អត្ថប្រយោជន៍ ឬឱកាសនៃការអប់រំផ្អែកលើកត្តាទាំងនេះដែរ។

## (4) ការហាមឃាត់ការសម្លុតធ្វើបាប ឬការបៀបបៀន

យើងមិននិយាយ ឬប្រព្រឹត្តទង្វើអ្វីមួយដែលធ្វើឲ្យអាប់ឱនដល់សេចក្តីថ្លៃថ្នូររបស់បុគ្គល ឬធ្វើឲ្យបានបង់ផលប្រយោជន៍ ឬគំរាមកំហែងដល់បុគ្គលទាំងឡាយ ផ្អែកលើបញ្ហានានាដូចជាយែនឌ័រ សិទ្ធិអំណាច ឬតួនាទី (ដូចជាការបៀបបៀនផ្លូវភេទ ឬការបៀបបៀនដោយប្រើអំណាចជាដើម) ហើយយើងក៏មិនជាប់ពាក់ព័ន្ធនឹងទម្រង់នៃការសម្លុតធ្វើបាប ឬការបៀបបៀនផ្សេងទៀតដែរ។

## (5) ការការពារសិទ្ធិឯកជនភាព

យើងមិនចែករំលែក ឬបញ្ចេញព័ត៌មានដែលពាក់ព័ន្ធនឹងជីវិតឯកជនរបស់បុគ្គលដែលទទួលបាននៅក្នុងកន្លែងការងារ ឬអំឡុងពេលបំពេញភារកិច្ចរបស់យើង ដោយមិនមានការយល់ព្រមច្បាស់លាស់ពីបុគ្គលដែលពាក់ព័ន្ធនោះឡើយ។ យើងនឹងគ្រប់គ្រងយ៉ាងសមស្របរាល់ទិន្នន័យបុគ្គលណាមួយដែលយើងទទួលបាន ស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមានទាំងអស់។

## (6) ការលើកម្ពស់តុល្យភាពរវាងការងារ និងជីវិត

យើងមានគោលបំណងគាំទ្រដល់ការអនុវត្តការងារល្អនៃនិយោជិតនៅកន្លែងធ្វើការ និងស្ថានភាព និងទំនួលខុសត្រូវផ្ទាល់ខ្លួនរបស់ពួកគេ។ ដើម្បីសម្រេចគោលដៅនេះ យើងនឹងសហការគ្នាបន្តអភិវឌ្ឍជំនាញវិជ្ជាជីវៈផ្ទាល់ខ្លួនរបស់យើង បុគ្គលិករួមការងាររបស់យើង និងបុគ្គលិកដែលយើងមានទំនាក់ទំនងជាមួយអំឡុងពេលបំពេញភារកិច្ចរបស់យើង ដោយយើងត្រូវគោរពចំពោះតម្រូវការបុគ្គល និងយល់ដឹងពីស្ថានភាពបុគ្គល រួមទាំងការទទួលខុសត្រូវថែទាំគ្រួសារ មានដូចជាការថែទាំកូន និងការបីបាច់ថែរក្សាជាដើម។

## (7) ការហាមឃាត់ចំពោះការងារដោយបង្ខំ/ពលកម្មកុមារ

យើងមិនពាក់ព័ន្ធនឹងរាល់ទម្រង់នៃការបង្ខំឲ្យធ្វើការងារ ឬពលកម្មកុមារគ្រប់រូបភាព រួមទាំងការងារជាទាសករ ការងារសងបំណុល ឬការជួញដូរមនុស្សជាដើម។ យើងជំរុញឲ្យមានការជ្រើសរើសការងារដោយសេរី តាម រយៈកិច្ចដំណើរការងារដ៏សមស្រប និងត្រូវចាត់វិធានការចាំបាច់ដើម្បីបង្ការការងារដោយបង្ខំ និងពលកម្មកុមារ។

## (8) លើកកម្ពស់សុខភាព និងសុវត្ថិភាពការងារ

យើងគោរពតាមច្បាប់ និង បទបញ្ញត្តិជាធរមានស្តីពីសុខភាព និងសុវត្ថិភាពការងារដូចជាច្បាប់និង បទបញ្ញត្តិទាំងឡាយណាដែលបង្កើតឡើងដើម្បីការពារគ្រោះថ្នាក់នៅកន្លែងការងារ។ យើងនឹងផ្តល់នូវការពិចារណាយ៉ាងដិតដល់ចំពោះសុខភាពផ្លូវកាយ និងផ្លូវចិត្តរបស់ពួកយើងផ្ទាល់ សហការីរបស់យើង និងបុគ្គលិកដែលយើងធ្វើការងារជាមួយ និងមានបំណងថែរក្សា និងលើកកម្ពស់បរិយាកាសការងារដែលសមស្រប មានសុខភាពល្អ និងមានសុវត្ថិភាព។

## (9) ការគោរពសិទ្ធិការងារ

យើងគោរព និងមិនបំពារបំពានលើសិទ្ធិការងារ ស្របទៅតាមច្បាប់ក្នុងស្រុក និងការអនុវត្តនានាដែលបានបង្កើតឡើងរួមមានសិទ្ធិរបស់បុគ្គលិកនៅក្នុងការរៀបចំ និងការចរចាសមូហភាពជាដើម។



## 2. សកម្មភាពសាជីវកម្មប្រកបដោយយុត្តិធម៌

យើងខិតខំប្រឹងប្រែងដើម្បីធានាថាសកម្មភាពសាជីវកម្មដែលយើងចូលរួម គឺមានភាពបើកទូលាយ យុត្តិធម៌ និងច្បាស់លាស់។ ការបំពារបំពានលើចំណុចដែលមានចែងនៅខាងក្រោម មិនត្រឹមតែអាចនាំទៅរកការដាក់ទណ្ឌកម្មផ្លូវច្បាប់ប៉ុណ្ណោះទេ តែថែមទាំងនាំឲ្យមានការបាត់បង់ទំនុកចិត្តពីក្រុមហ៊ុនទៀតផង។ យើងនឹងគោរពតាមចំណុចទាំងនេះ និងផ្តោតលើការប្រតិបត្តិក្រមសីលធម៌ខ្ពស់។ សកម្មភាពសាជីវកម្មរបស់យើង នឹងធ្វើការរាយការណ៍បានទាន់ពេលវេលា និងយ៉ាងត្រឹមត្រូវ តាមរយៈថ្នាក់គ្រប់គ្រង ហើយរាល់ចំណាត់ការនៃនីតិវិធីដែលបង្កើតឡើង ត្រូវយកមកអនុវត្ត។

### (1) ទំនាក់ទំនងសកម្ម

យើង ផ្តល់អាទិភាពដល់ការប្រាស្រ័យទាក់ទងផ្លោះប្តូរយោបល់គ្នាទៅវិញទៅមកទាំងខាងក្នុង និងខាងក្រៅដើម្បីឆ្លើយតបលើតម្រូវការសង្គម និងដើម្បីជំរុញដល់ការអភិវឌ្ឍទាំងអស់គ្នាស្របទៅតាមសង្គម និងរក្សាបាននូវឥរិយាបថបើកទូលាយ យុត្តិធម៌ និងច្បាស់លាស់ និងគោលជំហរនៅក្នុងការអនុវត្តសកម្មភាពសាជីវកម្មរបស់យើង។

### (2) ការបញ្ចេញព័ត៌មាន

យើងបង្កើតនូវគណនេយ្យភាពតាមរយៈការផ្សព្វផ្សាយព័ត៌មានសាជីវកម្មរបស់យើងយ៉ាងសកម្ម និងសមស្រប ដែលព័ត៌មានទាំងនោះរួមមានសកម្មភាព និងគោលនយោបាយស្តីពីការគ្រប់គ្រងរបស់យើង ទៅដល់ភាគីពាក់ព័ន្ធផ្សេងៗមានដូចជាអតិថិជន ដៃគូអាជីវកម្ម និយោជិត សហគមន៍ក្នុងស្រុក ទីភ្នាក់ងារ រដ្ឋាភិបាល ភាគីពាក់ព័ន្ធ និងអ្នកវិនិយោគផ្សេងទៀត ព្រមទាំងអង្គការក្រៅរដ្ឋាភិបាល និងអង្គការមិនស្វែងរកផលចំណេញផ្សេងទៀត។

## (3) ការប្រកួតប្រជែងដោយយុត្តិធម៌

យើងទទួលស្គាល់ សារៈសំខាន់នៃការប្រកួតប្រជែងទីផ្សារសេរី ហើយមិនអនុវត្តនូវការរឹតបន្តឹងផ្នែកពាណិជ្ជកម្មមិនសមស្រប ឬប្រើប្រាស់វិធីសាស្ត្រពាណិជ្ជកម្មមិនយុត្តិធម៌ត្រឹមត្រូវ ដែលអាចរារាំងដល់ការប្រកួតប្រជែងដោយយុត្តិធម៌នេះឡើយ។

## (4) សកម្មភាពនៃការលក់ដោយយុត្តិធម៌

យើងរក្សាបាននូវការអនុវត្តការលក់ដោយយុត្តិធម៌ និងសមធម៌ជាមួយនឹងអតិថិជន និងដៃគូលក់ដូចជាអ្នកចែកចាយបន្តជាដើម។ យើងមិនចូលរួមទៅក្នុងការអនុវត្តការលក់មិនសមស្របពាក់ព័ន្ធនឹងអតិថិជន និងដៃគូលក់ដូចជាការក្លែងបន្លំកំណត់ត្រាលក់ជាដើម ហើយយើងក៏មិនចូលរួមទៅក្នុងសកម្មភាពដែលអាចបណ្ដាលឲ្យមានការជាប់សង្ស័យសមស្របណាមួយទៅលើការ ឃោសនាជាមួយអតថិជន និងដៃគូលក់ផងដែរ។

## (5) ការធ្វើលទ្ធកម្មដោយយុត្តិធម៌

យើងរក្សាបាននូវភាពត្រឹមត្រូវយុត្តិធម៌ក្នុងទំនាក់ទំនងរបស់យើងជាមួយអ្នកផ្គត់ផ្គង់។យើងមិនចូលរួមក្នុងសកម្មភាពដែលអាចបំផ្លាញដល់ទំនាក់ទំនងយុត្តិធម៌ ជាមួយអ្នកផ្គត់ផ្គង់ដូចជាការទទួលយកផលប្រយោជន៍ផ្ទាល់ខ្លួន (ជាលុយកាក់ ជាវត្ថុ សេវាកម្មជាដើម) ឬ ការរំលោភបំពានតួនាទីចរចាក្រៅពីនេះឡើយ។

## (6) ការបង្ការអំពើពុករលួយ

យើងមានការប្រុងប្រយ័ត្ន និងយកចិត្តទុកដាក់ខ្ពស់នៅក្នុងទំនាក់ទំនងរបស់យើងជាមួយមន្ត្រីរដ្ឋាភិបាលក្នុងស្រុក និងក្រៅប្រទេស និងបុគ្គលិកសាធារណៈផ្សេងទៀត ហើយយើងមិនចូលរួមនៅក្នុងការប្រព្រឹត្តអំពើពុករលួយឡើយ។

## (7) ការហាមឃាត់ចំពោះអំពើពុករលួយ និងការរឹតបន្តឹងលើការដោះដូរជាអំណោយ និងការកម្សាន្ត

យើងមិន ចូលរួមនៅក្នុងការដោះដូរជាអំណោយ ឬការកម្សាន្ត ឬការផ្តល់នូវវិភាគទាន ការបរិច្ចាក ឬការឧបត្ថម្ភផ្នែកនយោបាយ ដែលអាចបំផ្លាញដល់ភាពយុត្តិធម៌ត្រឹមត្រូវ ឬបង់ប្រាក់សគុណជាថ្នូរទៅនឹងកិច្ចសន្យាឡើយ ដើម្បីឲ្យយើងអាចរក្សាបាននូវទំនាក់ទំនងល្អជាមួយអតិថិជន និងដៃគូអាជីវកម្មរបស់យើង រួមមានអ្នកចែកចាយ និងអ្នកផ្គត់ផ្គង់ជាដើម ហើយយើងអាចរក្សាបាននូវទំនាក់ទំនងដ៏មានកត្តិយស/ស្មោះត្រង់ជាមួយនឹង មន្ត្រីរដ្ឋាភិបាលក្នុងស្រុក និងក្រៅប្រទេស និងបុគ្គលិកសាធារណៈផ្សេងទៀត។

## (8) ការហាមឃាត់ចំពោះសកម្មភាពមនោគម វិជ្ជា/សកម្មភាពសាសនានៅក្នុងតួនាទីរបស់យើងជាបុគ្គលិកប្រតិបត្តិ និងនិយោជិត

យើងមិនប្រើប្រាស់តួនាទីរបស់យើងក្នុងនាមជាបុគ្គលិកប្រតិបត្តិ ឬនិយោជិតក្រុមហ៊ុន ដើម្បីគាំទ្រ ឬប្រឆាំងនឹងគណបក្ស ក្រុម ឬបេក្ខជននយោបាយណាមួយ ឬក្រុមមនោគម វិជ្ជា ឬសាសនាផ្សេងទៀតឡើយ។

## (9) ការច្រានចោលបទល្មើសគ្រោងទុកជាមុន

យើងបដិសេធមិនទទួលយកទំនាក់ទំនងណាមួយជាមួយនឹងក្រុមដែលពាក់ព័ន្ធនឹងសកម្មភាពខុសច្បាប់ ឬដែលគំរាមកំហែងដល់សណ្ដាប់ធ្នាប់ និងសុវត្ថិភាពសាធារណៈ ហើយយើងមិនធ្វើសកម្មភាពណាមួយដែល ផ្តល់ប្រយោជន៍ដល់ក្រុមទាំងនោះ មានដូចជាការជួយសម្រួលដល់ការលាងសម្អាតប្រាក់ជាដើម។

## (10) អនុសញ្ញាលើបទបញ្ញត្តិគ្រប់គ្រងពាណិជ្ជកម្ម

យើងគោរពតាមរាល់ បទបញ្ញត្តិ គ្រប់គ្រងពាណិជ្ជកម្មជាធរមានទាំងអស់ ដែលពាក់ព័ន្ធនឹងការនាំចេញ និងនាំចូលផលិតផល បច្ចេកវិទ្យា និងកម្មវិធីក៏ដូចជាការបញ្ចេញទៅខាងក្រៅនូវព័ត៌មានបច្ចេកវិទ្យា (រាប់បញ្ចូលការណែនាំអំពីបច្ចេកវិទ្យា) និងធ្វើការងារដើម្បីរក្សានូវសន្តិភាព និងសុវត្ថិភាពអន្តរជាតិ។

## (11) សុក្រឹតភាពនៃរបាយការណ៍ហិរញ្ញវត្ថុ និងការបង់ពន្ធសមស្រប

យើងព្យាយាមធ្វើឲ្យមាន សុក្រឹតភាពនៅក្នុងរបាយការណ៍គណនេយ្យ និងហិរញ្ញវត្ថុអំឡុងពេលនៃសកម្មភាពសាជីវកម្មរបស់យើង ហើយយើងមិនធ្វើការក្លែងបន្លំគណនី ឬចូលរួមទៅក្នុងសកម្មភាពណាមួយដែលពាក់ព័ន្ធនឹងការក្លែងបន្លំនោះឡើយ។ យើងគោរពតាមច្បាប់ពន្ធរបស់ប្រទេស និងតំបន់ដែលយើងដំណើរការអាជីវកកម្ម ក៏ដូចជាវិធានពន្ធអន្តរជាតិផងដែរ ហើយត្រូវបង់ពន្ធយ៉ាងសមស្របក្នុងប្រទេសឬតំបន់នីមួយៗនោះតាមច្បាប់កំណត់។

## (12) ការធានាគុណភាព/សុវត្ថិភាពនៃផលិតផល និងសេវាកម្ម

យើងធ្វើការធានាទាំងស្រុងថាផលិតផល និងសេវាកម្មរបស់យើង គឺមានសុវត្ថិភាព និង គុណភាពខ្ពស់ នៅក្នុងការផ្តល់សេវាកម្មនិងផលិតផលទាំងនេះទៅក្នុងទីផ្សារ។ យើងទទួលស្គាល់នូវសារៈសំខាន់នៃការរចនាជាសាកលដែលធានាថា ផលិតផល និងសេវាកម្មរបស់យើងអាចឲ្យមនុស្សគ្រប់រូបចូលប្រើប្រាស់បាន ដោយមិនគិតពីភាសា វប្បធម៌ សញ្ជាតិ អាយុ ភេទ ឬពិការភាពនោះទេ។ យើងក៏ផ្តល់ជូនផងដែរនូវការបិទស្លាក និងការបរិយាយត្រឹមត្រូវនិងងាយស្រួលយល់អំពីផលិតផលរបស់យើង និងការប្រើប្រាស់ផលិតផលទាំងនោះ ហើយខិតខំព្យាយាមបង្ការមិនឲ្យមានគ្រោះថ្នាក់កើតឡើង។ ក្នុងករណីមានគ្រោះថ្នាក់កើតឡើង យើងនឹងចាត់វិធានការដោះស្រាយឲ្យបានទាន់ពេលវេលា និងសមស្រប។

## (13) ការធ្វើទីផ្សារប្រកបដោយការទទួលខុសត្រូវ

យើងនឹងចុះធ្វើទីផ្សារ និងសកម្មភាពផ្សព្វផ្សាយពាណិជ្ជកម្មដែលផ្តល់នូវព័ត៌មានពិតត្រឹមត្រូវ ពាក់ព័ន្ធនឹងផលិតផល និងសេវាកម្មរបស់យើងទៅដល់អតិថិជន និងអ្នកប្រើប្រាស់។



# 3. ការការពារ/អភិរក្សទ្រព្យសម្បត្តិ និងព័ត៌មានសាជីវកម្ម

ក្រុមហ៊ុន មានទ្រព្យសម្បត្តិជាច្រើន។ នៅក្នុងការធ្វើអាជីវកម្មរបស់យើង យើងប្រើប្រាស់ទ្រព្យសម្បត្តិជាច្រើន មិនត្រឹមតែទ្រព្យសម្បត្តិសាជីវកម្មផ្ទាល់ខ្លួនរបស់យើងប៉ុណ្ណោះទេ តែថែមទាំងព័ត៌មានអតិថិជន និងទ្រព្យ រូបិយនិង អរូបិយច្រើនប្រភេទដែលពួកយើងរក្សាទុក តាមរយៈកិច្ចសន្យាជាមួយដៃគូពាណិជ្ជកម្ម និងសហការីរបស់យើង។ ដោយសារតែក្រុមហ៊ុនប្រឈមទៅនឹងការគំរាមកំហែងកាន់តែខ្លាំងឡើង មានដូចជាគ្រោះមហន្តរាយធម្មជាតិ បទល្មើសគ្រោងទុកជាមុន ភេរវកម្ម និងការវាយប្រហារតាមអ៊ីនធឺណិត ដូច្នេះយើងត្រូវតែការពារទាំងទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់យើង និងសិទ្ធិទ្រព្យសម្បត្តិរបស់ភាគីទីបីទាំងអស់នេះពីការគំរាមកំហែងទាំងនោះ។ ក្នុងរយៈពេលធ្វើការងាររបស់យើងពីមួយថ្ងៃទៅមួយថ្ងៃ ការយកចិត្តទុកដាក់គ្រប់គ្រងព័ត៌មាន និងទ្រព្យសម្បត្តិដែលយើងគ្រប់គ្រង និងការចាត់វិធានការបង្ការដើម្បីការពារគ្រោះថ្នាក់ និងជៀសវាងការបញ្ចេញព័ត៌មានមិនសមស្រប គឺរឿងដ៏មានសារៈសំខាន់កាន់តែខ្លាំងឡើង។

## (1) ការប្រើប្រាស់ដ៏មានប្រសិទ្ធភាពនៃទ្រព្យសម្បត្តិសាជីវកម្ម

យើងប្រើប្រាស់ទ្រព្យ រូបិយនិងអរូបិយនៃសាជីវកម្ម យ៉ាងសកម្ម និងមានប្រសិទ្ធភាព ដែលនោះគឺ គន្លឹះនៃការគ្រប់គ្រងធនធានដ៏សំខាន់មួយ ដើម្បីផ្តល់ជូននូវផលិតផល និងសេវាកម្មដែលមានលក្ខណៈជាបច្ចេកវិទ្យាកម្មសិទ្ធិបញ្ញាឈានមុខគេ។

## (2) ការហាមឃាត់ការប្រើប្រាស់ទ្រព្យសម្បត្តិសាជីវកម្មមិនសមស្រប

យើងគ្រប់គ្រង និងប្រើប្រាស់ទ្រព្យសម្បត្តិសាជីវកម្មរូបិយ និងអរូបិយយ៉ាងសមស្របដូចជាផលិតផល សម្ភារៈ គ្រឿងបរិក្ខារ ព័ត៌មាន និងកម្មសិទ្ធិបញ្ញា។ យើងមិនប្រើប្រាស់ទ្រព្យសម្បត្តិទាំងនោះសម្រាប់ជាផលចំណេញផ្ទាល់ខ្លួន ឬសម្រាប់គោលបំណងមិនសមស្របផ្សេងទៀតឡើយ ហើយក៏មិនធ្វើសកម្មភាពក្នុងលក្ខណៈដែលអាចបំផ្លាញ ឬកាត់បន្ថយតម្លៃនៃទ្រព្យសម្បត្តិទាំងនោះដែរ។

## (3) ការហាមឃាត់ចំពោះទំនាស់ផលប្រយោជន៍

យើងមិនប្រព្រឹត្តទង្វើទាំងឡាយណាដែលចាត់ទុកផលប្រយោជន៍បុគ្គលផ្ទាល់ខ្លួន ឬផលប្រយោជន៍គ្រួសារ មិត្តភក្តិ ឬអ្នកស្គាល់គ្នា សំខាន់ជាងផលប្រយោជន៍ក្រុមហ៊ុនឡើយ។ ឧទាហរណ៍ យើងមិនត្រូវប្រកួតប្រជែងជាមួយអាជីវកម្មរបស់ក្រុមហ៊ុន ជាប់ពាក់ព័ន្ធនឹងអាជីវកម្មប្រកួតប្រជែងទាំងនោះ ឬធ្វើការងារសម្រាប់ជាប្រយោជន៍ដល់ដៃគូប្រកួតប្រជែងរបស់ក្រុមហ៊ុននោះទេ។

## (4) ការហាមឃាត់ ការជួញដូរ ផ្ទៃក្នុង

យើងមិនត្រូវប្រព្រឹត្តទង្វើណាមួយដែលបង្កើតឡើងដើម្បីនាំមកនូវអត្ថប្រយោជន៍បុគ្គលដូចជាការជួញដូរភាគហ៊ុន ឬមូលបត្រផ្សេងទៀតដោយផ្អែកលើចំណេះដឹងដែលមិនមានការដឹងឮជាសាធារណៈ ទទួលបានអំឡុងពេលបំពេញភារកិច្ចរបស់យើង ឬទទួលបានជាពិសេសពីដៃគូអាជីវកម្ម និងបុគ្គលផ្សេងទៀតដោយប្រើប្រាស់តួនាទីរបស់យើងក្នុងនាមជាបុគ្គលិកប្រតិបត្តិ ឬនិយោជិត (ការជួញដូរ ផ្ទៃក្នុង)។

## (5) ការការពារព័ត៌មានសម្ងាត់

យើងទទួលស្គាល់ថា ព័ត៌មានសម្ងាត់សាជីវកម្ម គឺជាទ្រព្យដ៏សំខាន់ ហើយត្រូវគ្រប់គ្រងវាដោយមានការប្រុងប្រយ័ត្នខ្ពស់ដើម្បីរក្សាការសម្ងាត់។

## (6) ការការពារកម្មសិទ្ធិបញ្ញារបស់អ្នកដទៃ

យើងមិនត្រូវទទួលយក ឬប្រើប្រាស់មិនត្រឹមត្រូវនូវព័ត៌មានដែលមិនមានការដឹងឮជាសាធារណៈ ហើយជាកម្មសិទ្ធិរបស់អ្នកដទៃឡើយ។ យើងក៏មិនបំពារបំពានលើសិទ្ធិកម្មសិទ្ធិបញ្ញារបស់អ្នកដទៃដូចជាសិទ្ធិថតចម្លង ឬសិទ្ធិ ប៉ាតង់ជាដើម។

## (7) ការការពារព័ត៌មានផ្ទាល់ខ្លួន

យើងទទួលស្គាល់អំពីភាពរសើបនៃព័ត៌មានផ្ទាល់ខ្លួន ហើយត្រូវគ្រប់គ្រងព័ត៌មានទាំងនេះយ៉ាងសមស្រប និងគោរពតាមច្បាប់ និងបទប្បញ្ញត្តិជាធរមានពាក់ព័ន្ធនឹងការប្រមូលយក ការកត់ត្រា ការគ្រប់គ្រង ការប្រើប្រាស់ ការបញ្ចេញព័ត៌មានរសើបទាំងនោះ។

## (8) ការគ្រប់គ្រងវិបត្តិ

យើងធ្វើការគ្រប់គ្រងវិបត្តិជាប្រព័ន្ធ នៅក្នុងការត្រៀមរៀបចំសម្រាប់ការឆ្លើយតបជាបន្ទាន់នឹងការគំរាមកំហែងនានាដូចជាគ្រោះមហន្តរាយធម្មជាតិ ភេរវកម្ម និងការវាយប្រហារតាម អ៊ីនធឺណិត។ ប្រសិនបើករណីនោះកើតឡើង យើងនឹងធ្វើការងារដើម្បីកាត់បន្ថយផលប៉ះពាល់អតិបរមាលើភាគីដែលពាក់ព័ន្ធ ដោយ ផ្តល់អាទិភាពលើសុវត្ថិភាពរបស់និយោជក និងប្រជាពលរដ្ឋក្នុងមូលដ្ឋាន។



# 4. វិធានការពាក់ព័ន្ធនឹងបញ្ហាបរិស្ថាន

បញ្ហាបរិស្ថាន គឺជាឧបសគ្គចម្បងដែលមនុស្សជាតិជួបប្រទះ ដែលបញ្ហាទាំងនេះមិនអាចដោះស្រាយបានដោយតំបន់ ឬប្រជាជាតិណាមួយតែម្នាក់ឯងបានឡើយ។ ចាំបាច់ត្រូវមានកិច្ចសហការរវាងបុគ្គល អាជីវកម្ម សហគមន៍ក្នុងស្រុក និងភាគីពាក់ព័ន្ធជាច្រើនផ្សេងទៀត។ ក្រៅពីការអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន យើងពង្រឹងប្រព័ន្ធគ្រប់គ្រងបរិស្ថានរបស់យើង ដើម្បីកាត់បន្ថយបន្ទុកបរិស្ថាននៅគ្រប់ដំណាក់កាលទាំងអស់នៃកម្មភាពសាជីវកម្មរបស់យើង រាប់ចាប់ពីការធ្វើលទ្ធកម្មវត្ថុធាតុដើមរហូតដល់ការអភិវឌ្ឍផលិតផល ឧស្សាហកម្មផលិត ការដឹកជញ្ជូនការលក់ និងការផ្តល់សេវាកម្ម ការប្រើប្រាស់របស់អតិថិជន និងការបញ្ចប់អាយុកាលប្រើប្រាស់ផលិតផល។ លើសពីនេះទៀត យើងមានបំណងរួមចំណែកដោះស្រាយឧបសគ្គផ្នែកបរិស្ថានតាមរយៈបច្ចេកវិទ្យា និងការច្នៃប្រឌិតឈានមុខគេ។ ដើម្បីផ្តល់នូវពិភពលោកដែលមិនអាចជំនួសបាននេះទៅដល់មនុស្សជំនាន់ក្រោយ ចាំបាច់ត្រូវមានការយល់ដឹងបុគ្គល និងសកម្មភាពស្ម័គ្រចិត្តរបស់និយោជិតគ្រប់រូប។

## (1) ការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ

យើងទទួលស្គាល់ថាការវិវឌ្ឍឈានឡើងនៃការប្រែប្រួលអាកាសធាតុដែលបង្កឡើងដោយមនុស្ស គឺជាឧបសគ្គជាសកលមួយ ហើយយើងត្រូវធ្វើការងារឆ្ពោះទៅរកសង្គមមួយដែលគ្មានឧស្ម័នកាបូនិច (carbon neutral society)។ យើងនឹងផ្សព្វផ្សាយវិធានការនានាឲ្យបានទាន់ពេលវេលា ដើម្បីកាត់បន្ថយការបញ្ចេញ ឧស្ម័នផ្ទះកញ្ចក់ និងការគ្រប់គ្រងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុនៅគ្រប់សកម្មភាពអាជីវកម្មរបស់យើងទាំងអស់។

## (2) ការរួមចំណែកនៅក្នុងសេដ្ឋកិច្ចវិលជុំ

យើងទទួលស្គាល់ថាធនធាន គឺនៅមានកំណត់ ហើយយើងនឹងធ្វើការងារឆ្ពោះទៅរកការបង្កើតប្រព័ន្ធសេដ្ឋកិច្ចវិលជុំតាមរយៈ ការលើកកម្ពស់ ការកាត់បន្ថយ ការប្រើប្រាស់ឡើងវិញ និងការកែច្នៃឡើងវិញនូវធនធាននានា។

## (3) សុវត្ថិភាព និងការប្រើប្រាស់ដ៏មានប្រសិទ្ធភាពនៃសារធាតុគីមី

យើងនឹងចាត់វិធានការចាំបាច់នានានៅក្នុងការអភិវឌ្ឍ ការផលិត ការប្រើប្រាស់ និងបោះចោលសារធាតុគីមី ដើម្បីជៀសវាងផលប៉ះពាល់ជាអវិជ្ជមានចំពោះសុខភាពមនុស្ស និងបរិស្ថាន។ ម្យ៉ាងទៀត យើងនឹងបង្កើតនូវប្រសិទ្ធភាពជាអតិបរមានៃសារធាតុគីមី ដើម្បីជួយដោះស្រាយបញ្ហាសង្គមជាច្រើនទៀត។

## (4) ការការពារបរិស្ថានក្នុងស្រុក និងភាពជាដៃគូជាមួយសហគមន៍មូលដ្ឋាន

យើងក្នុងនាមជាសមាជិកនៃសហគមន៍មូលដ្ឋាន នឹងសហការដៃគូជាមួយភាគីពាក់ព័ន្ធផ្សេងៗ ដើម្បីការពារខ្យល់អាកាស ដី និងទឹក ដើម្បីកាត់បន្ថយការបំពុលដោយសំឡេង រំញ័រ និងក្លិន និងដើម្បីអភិរក្ស ជីវចម្រុះ។

# ការប្រើប្រាស់ប្រព័ន្ធផ្តុំកញ្ចែ

មន្ត្រី និងនិយោជិតអាចពិគ្រោះ ឬរាយការណ៍ពីកង្វល់ទៅប្រព័ន្ធផ្លុំកញ្ចែ នៅពេលដែលមានសំណួរទាក់ទងនឹងក្រមសីលធម៌កើតឡើងឬនៅពេលដែលមានការបំពានលើក្រមសីលធម៌ត្រូវបានកំណត់អត្តសញ្ញាណ។គោលបំណងនៃប្រព័ន្ធផ្លុំកញ្ចែគឺដើម្បីបង្កើតបរិយាកាសក្រុមហ៊ុនឱ្យកាន់តែប្រសើរឡើង ខណៈដែលបង្ការបញ្ហាតូចតាចនៅកន្លែងធ្វើការរបស់អ្នកពីការរាលដាលទៅជាបញ្ហាធ្ងន់ធ្ងរ។ គោលការណ៍ជាមូលដ្ឋានគឺថាបញ្ហាដែលកើតឡើងនៅកន្លែងធ្វើការរបស់អ្នកគួរតែត្រូវបានដោះស្រាយនៅក្នុងកន្លែងធ្វើការ។ ទោះជាយ៉ាងណាក៏ដោយ អ្នកអាចរាយការណ៍ និងស្វែងរកជំនួយចំពោះបញ្ហាជាមួយផ្នែកអនុលោមភាពនៅក្នុងក្រុមហ៊ុនរបស់អ្នក ឬដោយទាក់ទងប្រព័ន្ធផ្លុំកញ្ចែនៅពេលអ្នកពិបាករាយការណ៍ពីកង្វល់របស់អ្នកទៅកាន់ថ្នាក់លើ។

- និយោជិតនឹងមិនត្រូវបានការធ្វើបាប ឬទទួលការសងសឹកណាមួយសម្រាប់ការធ្វើរបាយការណ៍ដោយសេចក្តីស្មោះត្រង់ទៅប្រព័ន្ធផ្លុំកញ្ចែនោះទេ។
- ការធ្វើរបាយការណ៍មិនពិត បង្ខូចកេរ្តិ៍ឈ្មោះ ឬព្យាបាទត្រូវបានហាមឃាត់។

សម្រាប់ព័ត៌មានបន្ថែមអំពីប្រព័ន្ធផ្លុំកញ្ចែ សូមចូលទៅកាន់គេហទំព័ររបស់ក្រុមហ៊ុន ឬផ្ទាំងអនុលោមភាពដែលផ្តល់ដោយក្រុមហ៊ុន និងទីស្នាក់ការកណ្តាលក្នុងតំបន់របស់អ្នក។